ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
សំណុំរឿងព្រហ្មទណ្ឌលេខៈ ៣៩០ អក ចុះ
ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០
សាលក្រមលេខៈ ៥១ "ណ"
ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាលបានបើកសវនាការនៅសាលាសវនាការ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះដូចតទៅៈ

## ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្តាល

## តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

## មេធាវី

លោក [redacted] ជាមេធាវីការពារក្តីឱ្យជនត្រូវចោទឈ្មោះ [redacted] លី និងប្តីឈ្មោះ [redacted] គី។

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៣៩០ អ.ក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទៈ

១.ឈ្មោះ [redacted] លី ភេទស្រី អាយុ ៥០ ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត និងទីលំ នៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ស្រួយ (រ) ម្តាយឈ្មោះ [redacted] ប៉ែត (រ) ប្តីឈ្មោះ ខួង គី មានកូនចំនួន ០៦ នាក់ ទោសពីមុន គ្មាន (ក្រៅឃុំ) ។

២.ឈ្មោះ [redacted] គី ហៅ វុទ្ធី ភេទប្រុស អាយុ ៤៩ ឆ្នាំ ជាតិខ្មែរ មានទីកន្លែង កំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ខួង (ស) ម្តាយឈ្មោះ [redacted] ហៀក (រ) ប្រពន្ធឈ្មោះ [redacted] លី មានកូនចំនួន ០៦ នាក់ ទោសពីមុន គ្មាន (ក្រៅឃុំ) ។

ជាប់ចោទពីបទៈ សម្លុតសាក្សី ប្រព្រឹត្តនៅភូមិក្បាលដំរីលើ ឃុំកំពុងកុង ស្រុក កោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣-០១-២០២០។ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៥៤៦ នៃក្រមព្រហ្មទណ្ឌ ។

៣.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ាងលីម ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្នភូមិត្រពាំងកេះ ឃុំត្រពាំងកេះ ស្រុកត្រាំកក់ ខេត្តតាកែវ។

## អង្គហេតុនៃរឿងមានដូចតទៅៈ

កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ស្ថិតនៅក្នុងភូមិក្បាលដំរីលើ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល វេលាម៉ោងប្រហែល ០៣ រសៀល មានឈ្មោះ [redacted] លី និងប្តីឈ្មោះ [redacted] គី ហៅវុទ្ធី បានមកផ្ទះខ្លួន តែពេលគាត់ផ្ទះខ្លួន គឺខ្លួនមិនបានទៅផ្ទះទេ ដោយគាត់បាននិយាយគំរាមប្រពន្ធខ្លួនឈ្មោះ [redacted] ស្រ៊ាន់ ម្តាយខ្លួនឈ្មោះ [redacted] យេង និងប្អូនបង្កើតខ្លួនឈ្មោះ ថាកុំឱ្យធ្វើសាក្សីឱ្យឈ្មោះ [redacted] សំរួល របស់សាលាដំបូងខេត្តក

ណ្ដាល ហើយបើខ្លួនមិនធ្វើតាមគាត់ទេ គាត់នឹងប្ដឹងទាមទារប្រាក់ពីខ្លួន ចំនួន ៥០០០(ប្រាំពាន់ដុល្លារអាមេរិក) តែខ្លួនមិនដឹងថាគាត់ប្ដឹងទាមទារប្រាក់ពីខ្លួនពីរឿងអ្វីនោះទេ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ: ៩៧៣ ដកសស/២០ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរ លេខ: ១៧៣០ ដកសព/២០ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាដំណោះស្រាយលេខ: ១៨៣៤ ដកដស ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ២១៨៧ ដកចត/២០ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] លី បានឆ្លើយថា៖ កាលពីថ្ងៃខែមិនចាំឆ្នាំ២០២០ វេលាម៉ោងប្រហែល១០ ព្រឹក ខ្លួនជិះកងម្នាក់ឯកទៅទិញឥវ៉ាន់ នៅផ្ទះឈ្មោះ [redacted]លាង ភេទប្រុស ពេលទៅដល់បានជួបយាយ យ៉េង ត្រូវជាម្ដាយរបស់ឈ្មោះ ទឹម ស៊ាងលីម ដែលមានផ្ទះជាប់គ្នាពេលនោះខ្លួនបាននិយាយថា យាយៗ ឯងដឹងគេជេរខ្លួនអត់? យាយយ៉េងបានឆ្លើយថា អត់ដឹងទេ ហើយខ្លួនបានជិះកង់ត្រឡប់មកផ្ទះវិញ។ ចំពោះបណ្ដឹងទាមទារសំណងជម្ងឺចិត្តចំនួន ១ ម៉ឺនដុល្លារអាមេរិក ខ្លួនមិនព្រមទេ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចជាការចោលប្រកាន់ បើខ្លួនបានប្រព្រឹត្ត ខ្លួនព្រមទទួលខុសត្រូវចំពោះមុខច្បាប់។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted]លី បានឆ្លើយថា៖ [redacted]គី ហៅ វុទ្ធី ខ្លួនមិនដឹងរឿងទេ ព្រោះខ្លួនមិននៅផ្ទះ ខ្លួនទៅគប់ជេរដីបាត់ហើយ ខ្លួនសុំបដិសេធទាំងស្រុង សូមឱ្យតុលាការជួយរកយុត្តិធម៌ខ្លួនផង។

-ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ាងលីម បានឆ្លើយថា៖ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី ខ្លួនទៅចំការលុះដល់ម៉ោង ១៧ និង ០០ នាទី បានត្រឡប់មកផ្ទះវិញស្រាប់តែម្ដាយបានប្រាប់ថា មានឈ្មោះ [redacted] លី និងប្ដីឈ្មោះ[redacted] គី ហៅ វុទ្ធី បានមកគំរាមគាត់ឱ្យប្រាប់កូនខ្លួន កុំឱ្យធ្វើសាក្សីឱ្យឈ្មោះ [redacted] សំរួល បើខ្លួននៅតែធ្វើសាក្សីឱ្យឈ្មោះ [redacted]សំរួល គេប្ដឹងឈ្មោះ [redacted] សំរួល យកតែ២០០០ ដុល្លារទេ តែចំពោះខ្លួនវិញ គេប្ដឹងយក ៥០០០ ដុល្លារ។ ឈ្មោះ [redacted]លី និងប្ដីឈ្មោះ [redacted] គី បានប្ដឹងឈ្មោះ [redacted]សំរួល ពីរឿងឈ្មោះ [redacted]សំរួល បានដេញឈ្មោះ [redacted] លី និងប្ដីឈ្មោះ[redacted] គី មិនឱ្យចូលផឹកស៊ីក្នុងផ្ទះគាត់ ដោយហេតុថា កាលពីចុងខែធ្នូ ឆ្នាំ២០១៩ ឈ្មោះនេះបានមកផឹកស៊ីម្ដងហើយ តែប្រពន្ធឈ្មោះ ស្រួល លី បានមកជេរប្ដី និងបានជេរអ្នកផឹកស៊ីជាមួយទៀតទើបឈ្មោះ[redacted] សំរួល មិនឱ្យចូលផឹកស៊ីជាមួយ ហើយមានការឈ្លោះគ្នា ហើយក៏ឃើញមានឈ្មោះ [redacted] លី ជាមួយប្រពន្ធឈ្មោះ ខ្លូង គី បានប្ដឹងឈ្មោះ [redacted] សំរួល ទៅឃុំកំពង់កុង តែដោះស្រាយមិនាបាន។ បន្ទាប់មកឈ្មោះ [redacted] លី និងប្ដីឈ្មោះ[redacted] គី បានប្ដឹងឈ្មោះ [redacted] សំរួល មកតុលាការតែខ្លួនមិនបានដឹងថាប្ដឹងរឿងអ្វីទេ។ បន្ទាប់ឈ្មោះ [redacted] សំរួល បានប្ដឹងឈ្មោះ [redacted]លី និងប្ដីឈ្មោះ[redacted] គី តបវិញពីរឿងឈ្មោះនេះបានជេរប្រមាថ និងជៀលត្មេះ ហើយបានឱ្យខ្លួនធ្វើសាក្សី ដោយពេលកើតហេតុខ្លួននៅទីនោះដែរ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ស្រួល លី និងឈ្មោះ[redacted] គី ជាប់ចោទពីបទ: សម្លុតសាក្សី ប្រព្រឹត្តនៅភូមិក្បាលដំរីលើ ឃុំកំពុងកុង ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី២៣-០១-២០២០ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៥៤៦ នៃក្រមព្រហ្មទណ្ឌ។ ទុកជាបានការទាំងស្រុង និងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារក្ដីឱ្យជនត្រូវចោទ បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដូចច្នេះស្នើសុំឱ្យតុលាការលើកលែងការចោទប្រកាន់មកលើកូនក្ដីរបស់ខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

*ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ*

**យល់ឃើញថា៖**

១-ពុំមានអំពើ សម្លុតសាក្សី ប្រព្រឹត្តនៅភូមិក្បាលដំរីលើ ឃុំកំពុងកុង ស្រុក កោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣-០១-២០២០ ទេ។

២-ចម្លើយជនជាប់ចោទឈ្មោះ [redacted] លី បានឆ្លើយថា៖ កាលពីថ្ងៃខែមិនចាំឆ្នាំ២០២០ វេលាម៉ោងប្រហែល១០ ព្រឹក ខ្លួនជិះកងម្នាក់ឯកទៅទិញឥវ៉ាន់ នៅផ្ទះឈ្មោះ [redacted]លាង ភេទប្រុស ពេលទៅដល់បានជួបយាយ យ៉េង ត្រូវជាម្តាយរបស់ឈ្មោះ [redacted] ស៊ាងលីម ដែលមានផ្ទះជាប់គ្នាពេលនោះខ្លួនបាននិយាយថា យាយៗ ឯងដឹងគេជេខ្លួនអត់? យាយយ៉េងបានឆ្លើយថា អត់ដឹងទេ ហើយខ្លួនបានជិះកង់ត្រឡប់មកផ្ទះវិញ។ ចំពោះបណ្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ១ ម៉ឺនដុល្លារអាមេរិក ខ្លួនមិនព្រមទេ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចជាការចោលប្រកាន់ បើខ្លួនបានប្រព្រឹត្ត ខ្លួនព្រមទទួលខុសត្រូវចំពោះមុខច្បាប់។

៣-ចម្លើយជនជាប់ចោទឈ្មោះ [redacted] លី បានឆ្លើយថា៖ [redacted] គី ហៅ វុទ្ធី ខ្លួនមិនដឹងរឿងទេ ព្រោះខ្លួនមិននៅផ្ទះ ខ្លួនទៅគប់ដេរដីបាត់ហើយ ខ្លួនសុំបដិសេធទាំងស្រុង សូមឱ្យតុលាការជួយរកយុតិធម៌ខ្លួនផង។

៤-ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ាងលីម បានឆ្លើយថា៖ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី ខ្លួនទៅចំការលុះដល់ម៉ោង ១៧ និង ០០ នាទី បានត្រឡប់មកផ្ទះវិញ ស្រាប់តែម្តាយបានប្រាប់ថា មានឈ្មោះ [redacted] លី និងប្តីឈ្មោះ [redacted] គី ហៅ វុទ្ធី បានមកគំរាមគាត់ឱ្យប្រាប់កូនខ្លួន កុំឱ្យធ្វើសាក្សីឱ្យឈ្មោះ [redacted] សំរួល បើខ្លួននៅតែធ្វើសាក្សីឱ្យឈ្មោះ [redacted] សំរួល គេប្តឹងឈ្មោះ [redacted] សំរួល យកតែ២០០០ ដុល្លារទេ តែចំពោះខ្លួនវិញ គេប្តឹងយក ៥០០០ ដុល្លារ។ ឈ្មោះ ស្រួល លី និងប្តីឈ្មោះ ខ្លង គី បានប្តឹងឈ្មោះ [redacted] សំរួល ពីរឿងឈ្មោះ [redacted] សំរួល បានដេញឈ្មោះ [redacted] លី និងប្តីឈ្មោះ [redacted] គី មិនឱ្យចូលផឹកស៊ីក្នុងផ្ទះគាត់ ដោយហេតុថា កាលពីចុងខែធ្នូ ឆ្នាំ២០១៩ ឈ្មោះនេះបានមកផឹកស៊ីម្តងហើយ តែប្រពន្ធឈ្មោះ [redacted] លី បានមកជេរប្តី និងបានជេរអ្នកផឹកស៊ីជាមួយទៀតទើបឈ្មោះ [redacted] សំរួល មិនឱ្យចូលផឹកស៊ីជាមួយ ហើយមានការឈ្លោះគ្នា ហើយក៏ឃើញមានឈ្មោះ [redacted] លី ជាមួយប្រពន្ធឈ្មោះ [redacted] គី បានប្តឹងឈ្មោះ [redacted] សំរួល ទៅឃុំកំពង់កុង តែដោះស្រាយមិនាបាន។ បន្ទាប់មកឈ្មោះ [redacted] លី និងប្តីឈ្មោះ [redacted] គី បានប្តឹងឈ្មោះ [redacted] សំរួល មកតុលាការតែខ្លួនមិនបានដឹងថាប្តឹងរឿងអ្វីទេ។ បន្ទាប់ឈ្មោះ [redacted] សំរួល បានប្តឹងឈ្មោះ [redacted] លី និងប្តីឈ្មោះ [redacted] គី តបវិញពីរឿងឈ្មោះនេះបានជេរប្រមាថ និងដៀលត្មេះ ហើយបានឱ្យខ្លួនធ្វើសាក្សី ដោយពេលកើតហេតុខ្លួននៅទីនោះដែរ។ ។

៥-ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងរប្បវេណីឈ្មោះ [redacted] ស៊ាងលីម និងសាក្សី ក៏ដូចជាភស្តុតាងផ្សេងៗ ឱ្យដឹងថា ឈ្មោះ [redacted] លី និងឈ្មោះ [redacted] គី ហៅ វុទ្ធី មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

៦-ជនជាប់ចោទឈ្មោះ [redacted] លី និងឈ្មោះ [redacted] គី គឺជាជនដែលមានស្មារតី និងកាយសម្បទាគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លី និងឈ្មោះ [redacted] គី មិនធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម ទេ។

៨-ពុំមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] លី និងឈ្មោះ [redacted] គី ហៅ វុទ្ធី ជាប់ចោទពីបទ៖ សម្លុតសាក្សី ប្រព្រឹត្តនៅភូមិក្បាលដំរីលើ ឃុំកំពុងកុង ស្រុក កោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣-០១-២០២០ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៥៤៦ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

## ហេតុដូច្នេះ តុលាការ
## សម្រេច

-អោយឈ្មោះ [redacted] លី និងប្តីឈ្មោះ [redacted] គី ហៅ វុទ្ធី (ដែលមានអត្តសញ្ញាណដូចខាងលើ) រួចខ្លួន ពីបទ៖ **សម្ពុតសាក្សី** ប្រព្រឹត្តនៅភូមិក្បាលដំរីលើ ឃុំកំពុងកុង ស្រុក កោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣-០១-២០២០ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៥៤៦ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លី និងឈ្មោះ [redacted] គី ហៅ វុទ្ធី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]

**បានជូនដំណឹង**

ថ្ងៃទី 24 ខែ មីនា ឆ្នាំ២០២១

**តំណាងអយ្យការ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្តាល. ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner